ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ១៧ ត្រីមាសទី ០១ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៧-០៣-២០១៧ -ព្រះរាជក្រម នស/រកម/០៣១៧/០០៣ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី គណបក្សនយោបាយ ១៦០៤


### ២~ព្រះរាជក្រឹត្យ


២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៨៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីរាជការ ០៦ រូប ជាទីប្រឹក្សាក្រសួងធម្មការ និងសាសនា ១៦១៤

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៨៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឡុង សុផាត** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ដោយមិនទទួលប្រាក់បៀវត្ស ១៦១៥

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម ឧត្តមសេនីយ៍ត្រី **អ៊ុយ សារឿន** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ដោយមិនយកប្រាក់បៀវត្ស ១៦១៦

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩១ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ៣៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន ១៦១៧

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩២ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ២២ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ១៦២០

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ១៦២២

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៩ រូប ១៦២៣

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៥ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **សេត ម្ហាំម៉ាត់ស៊ីស** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មកនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៦២៤

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៦ ស្តីពី ការតាំងស៊ប់ដល់មន្ត្រីរាជការ ៣៨ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសុខាភិបាល ១៦២៥

២៣-០២-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០២១៧/១៩៧ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២១ រូប ១៦២៨

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០៩-០២-២០១៧ -សេចក្តីសម្រេចលេខ ១៨៤/០២៤/២០១៧ កបធ.ច ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ លើសំណុំរឿងលេខ ៣២៧/០៦៥/២០១៧ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ ១៦៣០

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៥-០២-២០១៧ -អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពី ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ «រាម» លើផ្ទៃដីទំហំ ៣៨៤.៨៥៦ (បីរយសែសិបបួនពាន់ ប្រាំបីរយហាសិបប្រាំមួយ) ម៉ែត្រក្រឡា ស្ថិតក្នុងភូមិសាស្ត្រភូមិថ្មធំ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ១៦៣៧

២៤-០២-២០១៧ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពី វិធាន និងនីតិវិធីនៃការលើកលែង និងអនុគ្រោះពន្ធប្រថាប់ត្រា ១៦៤១

១៦-០២-២០១៧ -អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ១៦៤៦

១៦-០២-២០១៧ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិមកជាឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ១៦៤៨

១៦-០២-២០១៧ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៦៥០

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ១៦៥២

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ១៦៥៥

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៦៦៥

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦៦៦

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦៦៩

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦៧៤

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦៧៦

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៦៧៨

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦៧៩

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារថ្នាក់មាស ១៦៨១

១៧-០២-២០១៧ -អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦៨៣


## ២-សេចក្តីសម្រេច


២៧-០២-២០១៧ -សេចក្តីសម្រេចលេខ ១៣ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ១៦៨៤

០១-០៣-២០១៧ -សេចក្តីសម្រេចលេខ ១៤ សសរ ស្តីពី ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ១៦៨៦


## IV-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៦១ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន នៅគ្រឹះស្ថានអង្គរ ១៦៨៨

១៣-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៦៣ សហវ.ហក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៧ របស់អង្គភាពថវិកាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១៦៩៤

១៤-០២-២០១៧ -ប្រកាសអន្តរក្រសួងលេខ ១៦៤ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៧ របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១៦៩៨

# ព្រះរាជក្រម

នស/រកម/០៣១៧/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៥/០២៥/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ



## មាត្រាមួយ.-

ច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

-ចំណងជើងជំពូកទី៤ ត្រូវបានកែប្រែទៅជាជំពូកទី៤ថ្មី អង្គការនានា និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ ។

-ចំណងជើងជំពូកទី៩ ត្រូវបានកែប្រែទៅជាជំពូកទី៩ថ្មី វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ។

-មាត្រា ៦ មាត្រា ១២ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៩ មាត្រា ៣៤ និងមាត្រាទាំងឡាយពីជំពូកទី ៩ ដល់ជំពូកទី ១១ ត្រូវបានកែប្រែដូចខាងក្រោម ៖

### មាត្រា ៦.-ថ្មី

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោម ៖

១- ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ។

២- ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

៣- ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ។

៤- បង្កើតកងកម្លាំងប្រដាប់អាវុធ ។

៥- ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ ។

### មាត្រា ១២.-ថ្មី

មានតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី) ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន ។

### មាត្រា ១៧.-ថ្មី

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានអង្គការដឹកនាំយ៉ាងតិចដូចខាងក្រោម ៖

១-មហាសន្និបាត ឬសមាជ ឬអង្គការសមមូល ។

២-ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្តាល ឬអង្គការសមមូល ។

៣-គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល ។

៤-គណៈកម្មាធិការអាជ្ញាកណ្តាល ឬគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិវាទ ឬអង្គការសមមូល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ ។

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានប្រធាន និងអាចមានអនុប្រធានតាមការចាំបាច់ ។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើសដោយអនុវត្តតាមលក្ខន្តិកៈនៃ គណបក្សនយោបាយនីមួយៗ ។

អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្សនយោបាយត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ។

## មាត្រា ១៨.-ថ្មី

ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ)ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំ នៃគណបក្សនយោបាយបាន ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរ ។

-សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសលើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ ។

គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយដែលបាត់បង់តួនាទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃបាត់បង់តួនាទីនោះ ។

បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានតួនាទី ឬសិទ្ធិអំណាចប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណកម្មា-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ។

**មាត្រា ១៩.-ថ្មី**

ក្នុងរយៈពេលយ៉ាងយូរ ១៨០ (មួយរយប៉ែតសិប) ថ្ងៃ បន្ទាប់ពីគណបក្សនយោបាយត្រូវបានបង្កើតឡើងស្របតាមមាត្រា ៩ នៃច្បាប់នេះ គណបក្សនយោបាយនោះត្រូវស្នើសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជានីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ (បួនពាន់) នាក់ និងត្រូវបំពេញបែបបទ និងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ ។

គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជី ស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ មិនអាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

**មាត្រា ២៥.-ថ្មី**

គណបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅតុលាការកំពូល ។

តុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ ។

ក្រោយពីបានទទួលសេចក្តីសម្រេចរបស់តុលាការកំពូលដែលសម្រេចលើភាពត្រឹមត្រូវនៃខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

**មាត្រា ២៦.-ថ្មី**

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ត្រូវបញ្ជូនទៅក្រសួងមហាផ្ទៃនូវបញ្ជីឈ្មោះប្រធាន និងអនុប្រធាន នៃគណបក្សនយោបាយ ក្នុងករណីដែលមានអនុប្រធាន និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេប ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ) ។

ការផ្លាស់ប្តូរប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

អចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់សមាសភាពថ្មី ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ) ។

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះ សញ្ញាសម្គាល់ ទីស្នាក់ការកណ្តាល កែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ឬធ្វើវិសោធនកម្មលើលក្ខន្តិកៈបានស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ ។

## មាត្រា ២៩._ថ្មី

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយពីស្ថាប័នរដ្ឋ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ លើកលែងតែករណីដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ។

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស ។

## មាត្រា ៣៤._ថ្មី

គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ ។

## មាត្រា ៣៨._ថ្មី

គ្រប់គណបក្សនយោបាយទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាណាចក្រកម្ពុជា ។

ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម ៖

-ចេញលិខិតជូនដំណឹងឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់ ។

-ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាប់ ក្នុងករណីចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់ ។

-ប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ ។

**មាត្រា ៣៩.-ថ្មី**

ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀល ដោយក្រសួងមហាផ្ទៃ ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣១ នៃច្បាប់នេះ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃអាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់ ។

**មាត្រា ៤០.-ថ្មី**

គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងមហាផ្ទៃ ចំនួន ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។ ក្នុងករណីវិភាគទានដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា ២៩ ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃវិភាគទាននោះ ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃប្រាក់ពិន័យលើកមុន ហើយក្រសួងមហាផ្ទៃអាចប្តឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល ។

**មាត្រា ៤១.-ថ្មី**

ត្រូវផាកពិន័យជាប្រាក់ចំនួន ៣ ០០០ ០០០ (បីលាន)រៀល ដោយក្រសួងមហាផ្ទៃ ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ និងកថាខណ្ឌទី ២ មាត្រា ១៥ នៃច្បាប់នេះ ។

**មាត្រា ៤២.-ថ្មី**

ត្រូវពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន)រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ដល់ ០១(មួយ)ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្តករណីណាមួយដូចខាងក្រោម ៖



១-បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលក្រសួងមហាផ្ទៃមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ។

២-បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលតុលាការបានសម្រេចរំលាយជាស្ថាពរ។

៣-គ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ក្នុងរយៈពេលលើសពី ១៨០ (មួយរយប៉ែតសិប)ថ្ងៃ គិតចាប់ពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្ដោះអាសន្នដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

៤-នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយ ទោះជាមានសេចក្ដីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ ។

៥-នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសេចក្ដីសម្រេចស្ថាពររបស់តុលាការសម្រេចរំលាយគណបក្សនយោបាយនោះក៏ដោយ ។

**មាត្រា ៤៣.-ថ្មី**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃ ដូចមានចែងក្នុងជំពូកនេះ អាចប្ដឹងត៉ៅទៅតុលាការកំពូលក្នុងអំឡុងពេល ៣០( សាបសិប )ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្ដីសម្រេចនេះ ។ ក្នុងអំឡុងពេលនៃការប្ដឹងត៉ៅ និងអំឡុងពេលនៃការដោះស្រាយបណ្ដឹងត៉ៅ សេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្ដីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្ដោះអាសន្ន ។

**មាត្រា ៤៤.-ថ្មី**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ ថ្មី និងមាត្រា ៧ នៃច្បាប់នេះ តុលាការអាចសម្រេចដូចខាងក្រោម ៖

-ផ្អាកសកម្មភាពគណបក្សនយោបាយនោះក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។

-រំលាយគណបក្សនយោបាយនោះ ។

**មាត្រា ៤៥.-ថ្មី**

តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្ដឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល ។ ដោយឡែកចំពោះមាត្រា ៤២ ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

តំណាងមហាអយ្យការអមតុលាការកំពូលត្រូវចូលរួមសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្ដឹងដាក់ជូនតុលាការកំពូលពិនិត្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះសម្រាប់រយៈពេល ០៥(ប្រាំ) ឆ្នាំបាន ។

តុលាការកំពូលត្រូវសម្រេចសេចក្ដីលើអង្គហេតុ និងអង្គច្បាប់ ដោយសភាពេញអង្គ ។ សាលដីការបស់តុលាការកំពូលជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។

**មាត្រា ៤៦.-ថ្មី**

ការអនុវត្តជំពូកនេះ មិនរាំងរាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ៤៧.-ថ្មី**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨ (នីតិវិធីប្រតិបត្តិ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

**មាត្រា ៤៨.-ថ្មី**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះ ត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

**មាត្រា ៤៩.-ថ្មី (មាត្រា៤៤ ចាស់)**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥០.-ថ្មី (មាត្រា៤៥ ចាស់)**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៧

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

នស/រកម.១៧០៣.២៥៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ដលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ២៥៨ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១៨៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការ ០៦រូប ជាទីប្រឹក្សាក្រសួងធម្មការ និងសាសនា ៖

១-ឯកឧត្តម **មាស សារុន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២-ឯកឧត្តម **ហ៊ីង យ៉ាន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣-ឯកឧត្តម **ជា ណារ៉េត** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឯកឧត្តម **ដោក កុសល** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឯកឧត្តម **ជា ម៉ាន់ថេន** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៦-ឯកឧត្តម **ខៀវ ភក្តី** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១៥៩ ស.ណ
**សំណៅដែលមានតម្លៃជាការបែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៤៧.១៧០៤-១៩០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១៨៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំង និងផ្ដល់ឋានៈឯកឧត្ដម **ឡុង សុផាត** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ដោយមិនទទួលប្រាក់បៀវត្ស ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១៧០២.១៩១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ ១៩៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១៨០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តមឧត្តមសេនីយ៍ត្រី អ៊ុយ សារឿន អត្តលេខ ៦៧៥៨៥ ជាទីប្រឹក្សាសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ដោយមិនយកប្រាក់បៀវត្ស។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៧០២.១៩២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខៈ១៩៥ ស.ណ
**សំណៅចែកចាយមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/១៩១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ២៤ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៦ ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ជិម រដ្ឋា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ២. ឯកឧត្តម **ស្រ៊ុន ដារិទ្ធិ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៣. លោក **មាស សុផល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៣. លោក **មាស សុផល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៤. លោក **ខឹម ប៊ុនហេង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៥. លោក **កុច សុខាន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៦. ឯកឧត្តម **ម៉ាន់ មុនីនាថ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៧. លោក **ឌួន គង់** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៨. លោក **ឡុង រិទ្ធីរក្សា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៩. លោក **ម៉ម សុវណ្ណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ១០. ឯកឧត្តម **សុខ គាង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១១. ឯកឧត្តម **កែន សេរីរដ្ឋា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១២. លោក **អៀង សុវណ្ណាន់រ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៣. លោក **ទ្រិន សុខា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៤. លោក **គីម ណុង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៥. លោក **ហេង តារិទ្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៦. លោក **ឃិន សំរាយ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៧. លោក **សុខខេង នមិន្ទ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៨. លោក **ម៉ា ច័ន្ទសុធា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១៩. លោក **និន ម៉ាន់ថា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២០. លោក **រស់ សុវណ្ណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២១. លោក **តាំង ឌុ៉ច** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២២. លោកស្រី **ម៉ៅ សុខា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២៣. លោក **ហេង គួន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ២** : តម្លើងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ១១ រូប ពីឋានន្តរស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៦ ៖

| | | |
|---|---|---|
| ១. លោកជំទាវ **ចាន់ សុម៉ាលី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | |
|---|---|---|
| ២. លោក **គុជ កុសល** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣. លោក **ទឹម ម៉ានី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤. លោក **អេង គឹមសាន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥. លោក **អ៊ុក ណាវ៉ាន់** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៦. លោក **តាន់ ប៊ុនណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៧. លោក **ស៊ី រ៉ាមុនី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៨. លោក **សេង សោត** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៩. លោក **ពុទ្ធ សុរិទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១០. លោក **ខឹម សុវណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១១. លោក **ប៉ាក សុខារ៉ាវុត** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស. ១៧០២. ១៩៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៣ ស.ណ

**សំណៅចម្លងចេញពីសំណៅដើម** **សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥ ចុះថ្ងៃទី ១៧ ខែ មករាឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍ រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការ ២២ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៦ ៖

| | | | |
|---|---|---|---|
| ១- លោកជំទាវ **ខេង សំវ៉ាដា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ១ | ជាករណីពិសេស |
| ២- លោកជំទាវ **អ៊ឹង កន្ថាផាវី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ | |
| ៣- លោកស្រី **ឌិន ស៊ីម៉េត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ២ | ជាករណីពិសេស |
| ៤- លោកជំទាវ **ពេជ ពិទូប្បរង្សា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ | |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៥- លោក **ម៉ី ហ៊ីល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៦- លោកស្រី **ចក់ មើល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៧- លោកស្រី **សាត សាលីម** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ ជាករណីជាសេស |
| ៨- ឯកឧត្តម **ស សុធា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៩- លោកស្រី **ស៊ិន ចន្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១០- លោក **សាំង បូរ៉ែ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១១- លោក **ស៊ុំ ចណ្ណសាន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១២- លោកស្រី **អ៊ុក ណារី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៣- លោកស្រី **មាស សុខុម** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៤- លោកស្រី **ចាន់ សាម៉ឺឌី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៥- លោកស្រី **សុត ស៊ីថុន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៦- លោក **ម៉ែន ជា** | ពីវរមន្ត្រី ថ្នាក់លេខ.១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៧- លោកស្រី **គង់ សាឡុន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៨- លោកស្រី **តួច សារី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ១៩- លោកស្រី **ឌិត សេដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២០-លោកស្រី **ឈឹម ស៊ីណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២១- លោកស្រី **ស៊ុយ ឥន្ទ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ ជាករណីជាសេស |
| ២២- លោកស្រី **ឡុង សុឃាវី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ ជាករណីជាសេស |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៤ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

**ក- ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ :**

- ឧត្តមសេនីយ៍ត្រី **នាង ផានិត** អត្តលេខ ០៦២៤៦ ។

**ខ- ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី :**

១- វរសេនីយ៍ឯក **ហេង សុខា** អត្តលេខ ៣៣៦៣៧

២- វរសេនីយ៍ឯក **សំ ឈឿន** អត្តលេខ ០៦២៣២ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៧០៤. ១៩៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ:

**ក- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ:**

| | | |
|---|---|---|
| ១- ឧត្តមសេនីយ៍ត្រី | **សែម សុភាន់** | អត្តលេខ ០៦៧៨៤ |
| ២- ឧត្តមសេនីយ៍ត្រី | **ម៉ែន វណ្ណា** | អត្តលេខ ០១០៧៨ |
| ៣- ឧត្តមសេនីយ៍ត្រី | **ខៃ សុម៉ាលី** | អត្តលេខ ០១០៨០ |

**ខ- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី:**

| | | |
|---|---|---|
| ១- វរសេនីយ៍ឯក | **កៅ មុយឃាង** | អត្តលេខ ០៥៥៤៦ |
| ២- វរសេនីយ៍ឯក | **ម៉ៅ ចំរើន** | អត្តលេខ ០៣៥៦១ |
| ៣- វរសេនីយ៍ឯក | **ឌី ដាម៉ង់** | អត្តលេខ ៧៧៦៣៩ |
| ៤- វរសេនីយ៍ឯក | **អ៊ុយ វាសនា** | អត្តលេខ ៧៥៧៦៦ |
| ៥- វរសេនីយ៍ឯក | **សៀ ម៉ាច់** | អត្តលេខ ៥៧៤៥៧ |
| ៦- វរសេនីយ៍ឯក | **អ៊ឹម ថានី** | អត្តលេខ ០៩៨៦៣ |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៧០២. ១៩៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **សេត មូហាំម៉ាត់ស៊ុស** ពីឋានន្តរសក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មកឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៧៨១៦១ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៧០២. ១៩៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧

លេខៈ ២០២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ដល់មន្ត្រីរាជការ ៣៨ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦ ៖

| | | |
|---|---|---|
| ១- | លោក **កែវ អង្គារិទ្ធ** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២- | លោក **វិន ដេឡា** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | |
|---|---|
| ៣- លោក ហួត ច័ន្ទប៉ូលីដា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៤- លោក សែ សុភាព | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៥- លោកស្រី ប៉ក់ សុគន្ធា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៦- លោក សាយ សែនណារ៉ុង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៧- លោកស្រី ឈៀក គីមលី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៨៖ លោកស្រី សាន មុំ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៩- លោក បួរ សត្ថា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១០- លោក នេត្រ កាយារិទ្ធ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១១- លោក ឡេង ប៊ុនណាង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១២- លោក អ៊្លូ គីមឡាំង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៣- លោកស្រី អ៊ូ អង្គារ៉ា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៤- លោក ជិន ចាន់ធឿន | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៥- លោកស្រី ពេជ្រ រតនា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៦- លោក សុត វណ្ណាត | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៧- លោក ស៊ាង សារិទ្ធ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៨- លោក ផន ភន | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ១៩- លោក លី ហួត | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២០- លោក ឌួង សុជាតិ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២១- លោក ជា ពិសាល | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២២- លោកស្រី ព្រំ សេដាចរិយ៉ា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៣- លោកស្រី ហួត ចាន់ឌី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៤- លោក សុខ សុភា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៥- លោកស្រី ស្រុង ចរិយា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៦- លោក ហួន ឡៃហ៊ាក | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៧- លោក វេង សុខគេង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៨- លោក សោម ទីន | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ២៩- លោក ស ឈុនអ៊ី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៣០- លោក អៀ ស៊ីថា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៣១- | លោក **ឃុន បូរ័ត្ន** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៣២- | លោក **អ៊ិត សុផាន់ណា** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ |
| ៣៣- | លោកស្រី **សេង សិត្ថា** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៤- | លោក **ណី សុជាតិ** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៥- | លោក **ណាង បញ្ញា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៦- | លោកស្រី **សំរិទ្ធ ចាន់ដារ៉ែន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៧- | លោកស្រី **ម៉ាប់ សុខចាំង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៨- | លោក **ឡាំង ឡាទី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស/រកត/០២១៧/១៨៧*

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៥ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៧

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ ស្ដីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឲ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២១ រូប ៖

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | **សៅ ទិរៈឌុយ** | អត្តលេខ | ០៥៨៨ |
| ២- | ឧត្តមសេនីយ៍ឯក | **ឈិម សារ៉ាក់** | អត្តលេខ | ០១៤៤ |
| ៣- | ឧត្តមសេនីយ៍ឯក | **ឆយ ឈឿង** | អត្តលេខ | ០៨០៧ |
| ៤- | ឧត្តមសេនីយ៍ឯក | **គីម យ៉ីដេត** | អត្តលេខ | ២៤០៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៥- | ឧត្តមសេនីយ៍ទោ | **សេង ប៊ុនថន** | អត្តលេខ | ១០៤៧ |
| ៦- | ឧត្តមសេនីយ៍ទោ | **ជា យឿន** | អត្តលេខ | ០៩១៥ |
| ៧- | ឧត្តមសេនីយ៍ទោ | **គីម ខាសនា** | អត្តលេខ | ០៦៧០ |
| ៨- | ឧត្តមសេនីយ៍ទោ | **ពៅ យីន** | អត្តលេខ | ០១៥០ |
| ៩- | ឧត្តមសេនីយ៍ទោ | **ពេជ្រ យ៉ុន** | អត្តលេខ | ០៦៧៣ |
| ១០- | ឧត្តមសេនីយ៍ទោ | **គង់ សឿន** | អត្តលេខ | ០៧២៨ |
| ១១- | ឧត្តមសេនីយ៍ទោ | **ឌីម ណារិទ្ធ** | អត្តលេខ | ០៥៧៧ |
| ១២- | ឧត្តមសេនីយ៍ទោ | **អ៊ុច ធីរ** | អត្តលេខ | ០៣១៣ |
| ១៣- | ឧត្តមសេនីយ៍ទោ | **ខ្វាន់ ចន្ធី** | អត្តលេខ | ០៦១១ |
| ១៤- | ឧត្តមសេនីយ៍ទោ | **រស់ ស៊ីថាន** | អត្តលេខ | ០២៩០ |
| ១៥- | ឧត្តមសេនីយ៍ត្រី | **ឡុង សម៉យ** | អត្តលេខ | ១២៣៣៨ |
| ១៦- | ឧត្តមសេនីយ៍ត្រី | **ស្ងួន សាន់** | អត្តលេខ | ០៥១៦ |
| ១៧- | ឧត្តមសេនីយ៍ត្រី | **ទ៉ាន់ សារុន** | អត្តលេខ | ៥៤២៦ |
| ១៨- | ឧត្តមសេនីយ៍ត្រី | **យក់ ហុង** | អត្តលេខ | ០០៧៩ |
| ១៩- | ឧត្តមសេនីយ៍ត្រី | **សុខ ម៉ូរីត្យា** | អត្តលេខ | ២៤១០ |
| ២០- | ឧត្តមសេនីយ៍ត្រី | **អ៊ុង ធីរៈ** | អត្តលេខ | ១៣៥២ |
| ២១- | ឧត្តមសេនីយ៍ត្រី | **ព្រីល ទ៉ាន់ថន** | អត្តលេខ | ៤៩០២ ។ |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរម. ១៧០២. ១៩៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧*

លេខ: ២០៦ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ៣២៧/០៦៥/២០១៧
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧

**សេចក្តីសម្រេច**
លេខ : ១៨៤/០២៤/២០១៧ កបធ.ច
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៤៣ លេខ ០៤៤ លេខ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ១៤៧ លេខ ១៤៨ លេខ ១៤៩ លេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ ឆេង ស៊ីចូ ឈ្មោះ ហ៊ាប ផា ឈ្មោះ ហ៊ាប ហ៊ាញ ឈ្មោះ ជុំ សែម ឈ្មោះ រ៉ុម ចៀន ឈ្មោះ ហេង ប៊ុនថន ឈ្មោះ សេន សើ ឈ្មោះ អ៊ឹង អុន ឈ្មោះ សំ សុជាតិ ឈ្មោះ ហោ រតនា ឈ្មោះ យូម ដួង ឈ្មោះ កែវ សុធន់ ឈ្មោះ វ៉ាន់ សាវ៉ាន់ និង ឈ្មោះ អ៊ូ សារឹម ប្រគល់សិទ្ធិជូន

លោកមេធាវី ផែង ហេង ជាមេធាវីតំណាងក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ការពារសំណុំរឿងនៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី

- បានឃើញពាក្យបណ្តឹងរបស់លោកមេធាវី ផែង ហេង ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ លេខ ០៤៣ លេខ ០៤៤ លេខ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ លេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ លេខ ១៤៧ លេខ ១៤៨ លេខ ១៤៩ លេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី ផែង ហេង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ នៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៤៥ គ.ជ.ប ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមឯកឧត្តម មាន សទិ និង ឯកឧត្តម កែ រឹទ្ធិ មកបំភ្លឺលើពាក្យបណ្តឹងរបស់លោកមេធាវី ផែង ហេង
- បានឃើញកំណត់ហេតុបំភ្លឺរបស់ឯកឧត្តម មាន សទិ និង ឯកឧត្តម កែ រឹទ្ធិ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ ភ្ជាប់ដោយសារណាមួយច្បាប់ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ និងឯកសារពាក់ព័ន្ធនឹងអ្នកចុះឈ្មោះបោះឆ្នោតដែលត្រូវបានប្តឹងថាជាជនជាតិបរទេស
- បានឃើញកំណត់ហេតុ និង របាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៧ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោកមេធាវី ផែង ហេង ចុះថ្ងៃទី៣១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ថិតក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦ ចំណុចទី៣នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងរបស់លោកមេធាវី ផែង ហេង បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន លើកលែងតែបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៤៣ លេខ ០៤៤ លេខ ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកមេធាវី ផែង ហេង បានបញ្ជាក់ដូចតទៅនេះ ៖

- លោកនៅតែរក្សាពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ប្តឹងជំទាស់នឹងសេចក្តីសម្រេច ទាំង ១៥ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដដែល
- លោកមិននៅកន្លែងកើតហេតុទេ តែកូនក្តីឬដើមបណ្តឹងដឹងថាជនជាតិបរទេសទាំងនោះមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត តែត្រង់ថាលិខិត ឬឯកសារស្របច្បាប់ ឬមិនស្របច្បាប់ កូនក្តីនោះមិនដឹងទេ ដឹងត្រឹមថាអ្នកទាំងនោះជាជនជាតិវៀតណាម និង មានសាក្សីដែលស្គាល់ថា អ្នកទាំងនោះជាជនជាតិវៀតណាមមិនមានធ្វើសញ្ជាតូបនីយកម្ម
- ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យមើលថា ការចុះឈ្មោះបោះឆ្នោតមានឯកសារត្រឹមត្រូវ តាមច្បាប់ ឬមិនត្រឹមត្រូវ និង សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបញ្ជាទៅក្រុមជំនាញពិនិត្យបង្ហាញពី ការទទួលបានសញ្ជាតិរបស់អ្នកទាំងនោះ
- លោកមេធាវី ផែង ហេង សំណូមពរក្រុមប្រឹក្សាធម្មនុញ្ញកោះហៅជនដែលត្រូវប្តឹងចូលមក បំភ្លឺចំពោះមុខដើម្បីធ្វើការសាកសួរឬសគល់នៃការចូលសញ្ជាតិខ្មែរ ។ បើរកឃើញថាជន ទាំងនោះជាជនជាតិបរទេសដោយពុំបានធ្វើសញ្ជាតូបនីយកម្ម សូមលុបឈ្មោះចេញពីបញ្ជី បោះឆ្នោតដំបូងឆ្នាំ២០១៦។

- យល់ឃើញថា នៅពេលបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ។ឯកឧត្តមមាន សទិ និង ឯកឧត្តម តែ រឹទ្ធិ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺដូចខាងក្រោម៖
  - សេចក្តីសម្រេចលេខ ០៤៣ លេខ ០៤៤ លេខ ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចលេខ ១៦៩/00៩/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ រួចហើយ
  - សេចក្តីសម្រេចលេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ និង សេចក្តីសម្រេចលេខ ១៤៧ លេខ១៤៨ លេខ ១៤៩ លេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ លោកមេធាវី ផែង ហេង បាន អះអាងថាអ្នកចុះឈ្មោះបោះឆ្នោតទាំងនោះ ជាជនជាតិបរទេស និយាយភាសាខ្មែរមិនច្បាស់ មិនមានសញ្ជាតិខ្មែរ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៦នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ និង ពុំមានព្រះរាជក្រឹត្យផ្តល់សញ្ជាតិ ដែលផ្ទុយនឹងមាត្រា១៦ និង មាត្រា១៩នៃច្បាប់ស្តីពីសញ្ជាតិ ។ តាមការពិនិត្យនិងការស្រាវជ្រាវរបស់គណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត តាមរយៈឯកសាររបស់ក្រុមចុះឈ្មោះបោះឆ្នោតឃុំ-សង្កាត់ខាងលើ បញ្ជូនមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឃើញថា អ្នកចុះឈ្មោះបោះឆ្នោតបាន ប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយបានចុះឈ្មោះបោះឆ្នោតនៅមុខក្រុមចុះឈ្មោះ បោះឆ្នោតស្របតាមមាត្រា ៥១នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា ពាក្យបណ្ដឹងរបស់លោកមេធាវី ផែង ហេង ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ និង សេចក្ដីសម្រេចលេខ ១៤៧ លេខ ១៤៨ លេខ ១៤៩ លេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការសុំលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោត ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ ពុំមានឯកសារ ឬភស្តុតាងជាលាយលក្ខណ៍-អក្សរ ដែលអាចឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឡើយ
- យល់ឃើញថា តាមការស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អ្នកចុះឈ្មោះបោះឆ្នោតដែលត្រូវដើមបណ្ដឹងប្ដឹងសុំលុបឈ្មោះ អ្នកទាំងនោះសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ និង បទបញ្ជានិងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦
- យល់ឃើញថា សេចក្ដីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ និង សេចក្ដីសម្រេចលេខ ១៤៧ លេខ ១៤៨ លេខ ១៤៩ លេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា ពាក្យបណ្ដឹងរបស់លោកមេធាវី ផែង ហេង ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០៤៣ លេខ ០៤៤ និង លេខ ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យដោះស្រាយរួចហើយតាមសេចក្ដីសម្រេចលេខ ១៦៩/០០៩/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់លោកមេធាវី ផែង ហេង ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សេចក្ដីសម្រេចលេខ ១១៤ លេខ ១១៥ លេខ ១១៦ លេខ ១១៧ លេខ ១១៨ លេខ ១១៩ លេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ និង សេចក្ដីសម្រេចលេខ ១៤៧ លេខ ១៤៨ លេខ ១៤៩ លេខ ១៥០

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០២៧ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ១១៦ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១៤៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១៤៨ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១៤៩ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ១៥០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** មិនទទួលពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់លោកមេធាវី ផែង ហេង ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០៤៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៤៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ សេចក្តីសម្រេចលេខ ០៤៥ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ដោយខុសនឹងទម្រង់ច្បាប់។

**មាត្រា ៤.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**អ៊ឹម ឈុនលឹម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

BBC
LAW FIRM
BARRISTER AND BUSINESS CONSULTANT
ក្រុមហ៊ុនមេធាវីប៊ីប៊ីស៊ី

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ. ៥២/០៦៥/២០១៧
ថ្ងៃ. ៣១-០១-២០១៧
ម៉ោង. ...១៤:៣០...

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ០១ ឆ្នាំ២០១៧

# ពាក្យបណ្ដឹង

ខ្ញុំបាទមេធាវី **ផែន ហេង** ការិយាល័យផ្ទះលេខ១៤CE$_1$ ផ្លូវ៣៨៤ ភូមិ០៥ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទលេខ ០១២ ៨៥០ ២៨២ ជាមេធាវីតំណាងឱ្យដើមបណ្ដឹងដូចមានក្នុងលិខិតផ្ទេរសិទ្ធិខាងក្រោម។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ៖** ប្ដឹងជំទាស់នឹងសេចក្ដីសម្រេចលេខ៖
- ០២៧ ចុះថ្ងៃទី១៨/០១/២០១៧ នៃសំណុំរឿងលេខ ០៨៥ ចុះថ្ងៃទី១៣/០១/២០១៧
- ០៤៣ ចុះថ្ងៃទី១៩/០១/២០១៧ នៃសំណុំរឿងលេខ ១០១ ចុះថ្ងៃទី១៤/០១/២០១៧
- ០៤៤ ចុះថ្ងៃទី១៩/០១/២០១៧ នៃសំណុំរឿងលេខ ១០២ ចុះថ្ងៃទី១៤/០១/២០១៧
- ០៤៥ ចុះថ្ងៃទី១៩/០១/២០១៧ នៃសំណុំរឿងលេខ ១០៣ ចុះថ្ងៃទី១៤/០១/២០១៧
- ១១៤ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៣ ចុះថ្ងៃទី១៨/០១/២០១៧
- ១១៥ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៤ ចុះថ្ងៃទី១៨/០១/២០១៧
- ១១៦ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៥ ចុះថ្ងៃទី១៨/០១/២០១៧
- ១១៧ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៦ ចុះថ្ងៃទី១៨/០១/២០១៧
- ១១៨ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៧ ចុះថ្ងៃទី១៨/០១/២០១៧
- ១១៩ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៨ ចុះថ្ងៃទី១៨/០១/២០១៧
- ១២០ ចុះថ្ងៃទី២២/០១/២០១៧ នៃសំណុំរឿងលេខ ១៧៩ ចុះថ្ងៃទី១៨/០១/២០១៧
- ១៤៧ ចុះថ្ងៃទី២៣/០១/២០១៧ នៃសំណុំរឿងលេខ ២០៦ ចុះថ្ងៃទី២០/០១/២០១៧
- ១៤៨ ចុះថ្ងៃទី២៣/០១/២០១៧ នៃសំណុំរឿងលេខ ២០៧ ចុះថ្ងៃទី២០/០១/២០១៧
- ១៤៩ ចុះថ្ងៃទី២៣/០១/២០១៧ នៃសំណុំរឿងលេខ ២០៨ ចុះថ្ងៃទី២០/០១/២០១៧
- ១៥០ ចុះថ្ងៃទី២៣/០១/២០១៧ នៃសំណុំរឿងលេខ ២០៩ ចុះថ្ងៃទី២០/០១/២០១៧

របស់ គជប. ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) សរុបចំនួន៧៥នាក់ចេញពីបញ្ជីឈ្មោះបោះឆ្នោតដំបូង ឆ្នាំ២០១៦។

**យោង៖**
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្ដីឈ្មោះ ឆេង ស៊ីថូ
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្ដីឈ្មោះ ហ៊ាប ផា
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្ដីឈ្មោះ ហ៊ាប ហ៊ាញ

អាសយដ្ឋាន៖ ការិយាល័យផ្ទះ ១៤CE₀ ផ្លូវ ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel: (855)-12 850 282 / (855)-81 850 282, Email: lawfirmbbc@gmail.com, Blog: bbclawfirm.blogspot.com

- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ ជុំ សែម
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ រ៉ុម ចៀន
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ ហេង ប៊ុនថន
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ សេន សើ
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ អ៊ឹង អុន
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ សំ សុជាតិ
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ ហោ រតនា
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ យូម ដួង
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ កែវ សុធន
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ វ៉ាន់ សាវ៉ាន់
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០/០១/២០១៧ របស់កូនក្តីឈ្មោះ អ៊ូ សារឹម

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កូនក្តីខ្ញុំ កើតទុក្ខមិនសុខចិត្តនឹងការសម្រេចរបស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន៧៥នាក់ ចេញពីបញ្ជីឈ្មោះបោះឆ្នោតជំបូងឆ្នាំ២០១៦។ ការដែលកូនក្តីខ្ញុំបានប្តឹងឱ្យលុបឈ្មោះជនជាតិបរទេសទាំងនេះដោយសារ ជនទាំងនេះនិយាយខ្មែរមិនច្បាស់ និងអ្នកខ្លះ ឪពុកម្តាយជាជនជាតិវៀតណាមមិនដែលធ្លាប់បានធ្វើសញ្ជាតិតូបនីយកម្មម្តងណាឡើយ ហើយការសម្រេចសេចក្តីរបស់ គ.ជ.ប ក៏មិនបានឱ្យជនចុងចម្លើយមកចូលរួមដេញដោលការពារខ្លួននៅចំពោះមុខអង្គសវនាការដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធី ដោយអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.ឆែម ហេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ៣៤៤ ៨៥៦ (បីរយសែសិបបួនពាន់ ប្រាំបីរយហាសិបប្រាំមួយ) ម៉ែត្រក្រឡា ស្ថិតក្នុងភូមិសាស្ត្រភូមិថ្មធំ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់តំបន់ ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ៣.៣០០ហិកតា ក្នុងឧទ្យានជាតិព្រះសីហនុ«រាម» និងការធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.–**

ត្រូវបានកំណត់ជាតំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ៣៤៤៨៥៦ (បីរយសែសិបបួនពាន់ប្រាំបីរយហាសិបប្រាំមួយ) ម៉ែត្រក្រឡា សម្រាប់ផ្តល់ជូនប្រជាជនដែលរស់នៅក្នុងមូលដ្ឋាន ស្ថិតនៅក្នុងភូមិសាស្ត្រភូមិថ្មធំ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានទីតាំងកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមានចំណុចគោលតាមនិយាមកាដូចខាងក្រោម៖

| និយាមកាគោល | | | | | |
|---|---|---|---|---|---|
| No | X | Y | No | X | Y |
| 1 | 353575 | 1161919 | 4 | 354142 | 1161365 |
| 2 | 354099 | 1161919 | 5 | 354089 | 1161305 |
| 3 | 354239 | 1161632 | 6 | 353579 | 1161408 |

**មាត្រា២.–**

តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» ស្ថិតនៅក្នុងភូមិសាស្ត្រភូមិថ្មធំ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាជនមូលដ្ឋាន។ រាល់ការចេញប័ណ្ណសម្គាល់កម្មសិទ្ធដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*


ឧបសម្ព័ន្ធ៖ អនុក្រឹត្យលេខ
ផែនទីកំណត់តំបន់សហគមន៍ នៃតំបន់ឧទ្យានជាតិព្រះសីហនុ-រាម- លើផ្ទៃដីទំហំ ៣៤៤៨៥៦ ម៉ែត្រក្រឡា
ស្ថិតនៅភូមិសាស្ត្រ ភូមិថ្មធំ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
ផែនទី និងនិយាមកានេះជាឯកសារ
ភ្ជាប់នឹងលិខិតលេខ
រដ្ឋមន្ត្រីក្រសួងបរិស្ថាន
សាយ សំអាល់
សញ្ញាសម្គាល់
ផ្លូវ
ចំណុចនិយាមការ ព្រំប្រទល់សហគមន៍
តំបន់ស្នើសុំកំណត់តំបន់គ្រប់គ្រងជាតំបន់សហគមន៍
ឧទ្យានជាតិព្រះសីហនុ -រាម-
| Id | X | Y |
|---|---|---|
| 1 | 353575 | 1161919 |
| 2 | 354099 | 1161919 |
| 3 | 354239 | 1161632 |
| 4 | 354142 | 1161365 |
| 5 | 354089 | 1161305 |
| 6 | 353579 | 1161408 |
Projection: UTM
Datum: WGS 1984
Zone 48 North
Unit: Meters
មាត្រដ្ឋាន ១/៤០០០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## វិធាននិងនីតិវិធីនៃការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងផ្តល់នូវការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រា ដើម្បីសម្រាលបន្ទុកបង់ពន្ធរបស់ប្រជាពលរដ្ឋ។

**មាត្រា២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវវិធាននិងនីតិវិធីនៃការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រាចំពោះការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ការទទួលកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូន អនុលោមតាមមាត្រា១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**មាត្រា៣.- វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ ÷

- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល
- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ
- ការទទួលកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០សេះ។

**មាត្រា៤.- និយមន័យ**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម ÷

**រង្វង់ញាតិ** សំដៅដល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ÷

- រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត
- រវាងប្តីនិងប្រពន្ធ
- រវាងយាយ-តាបង្កើតនិងចៅបង្កើត
- រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត
- រវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ
- រវាងយាយ-តាក្មេកនិងចៅប្រសារ។

ប្រទានកម្ម សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

សន្តតិកម្ម សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ។

អចលនទ្រព្យ សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី (មានបណ្ណកម្មសិទ្ធិ) ឬមិនបានចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ) ដោយរដ្ឋបាលសុរិយោដី។

## ជំពូកទី២

## លក្ខខណ្ឌនៃការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រា

### មាត្រា៥.- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល

ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល ត្រូវបានលើកលែងពន្ធប្រថាប់ត្រាក្នុងករណីដែលសម្បទានដីនោះ ត្រូវបានធ្វើឡើងលើដីឯកជនរបស់រដ្ឋ សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន ឬ/និងធ្វើកសិ-ឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

ចំពោះការលើកលែងពន្ធប្រថាប់ត្រាដូចមានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវមានឯកសារជាភ័ស្តុតាងបញ្ជាក់អំពីការធ្វើសម្បទានដី។

### មាត្រា៦.- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ

ការលើកលែងនិងការអនុគ្រោះពន្ធប្រថាប់ត្រាលើការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ ត្រូវបានកំណត់ដូចតទៅ ÷

១- ត្រូវបានលើកលែងពន្ធប្រថាប់ត្រាលើការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះ ÷

- ការធ្វើសន្តតិកម្ម រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើត និងពីឪពុក-ម្តាយទៅឱ្យកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍
- ការធ្វើប្រទានកម្មលើកទី១ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើត ពីឪពុក-ម្តាយទៅឱ្យកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងពីយាយ-តាទៅឱ្យចៅបង្កើតនិងចៅប្រសារដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍-ពិពាហ៍។

២- ត្រូវបានអនុគ្រោះពន្ធប្រថាប់ត្រាលើការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដូចខាងក្រោម÷

- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ និងរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត ត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ២០០ ០០០ ០០០

(ពីររយលាន) រៀល ចំពោះការធ្វើសន្តតិកម្ម និងចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះការធ្វើប្រទានកម្ម

- ការធ្វើប្រទានកម្មអចលនទ្រព្យដែលចាប់ពីលើកទី២តទៅ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើត ពីឪពុក-ម្តាយទៅឱ្យកូនបង្កើតនិងកូនប្រសារ ដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងពី យាយ-តាទៅឱ្យចៅបង្កើតនិងចៅប្រសារដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល។

ការលើកលែងឬការអនុគ្រោះពន្ធប្រថាប់ត្រាក្នុងវង្វង់ញាតិខាងលើ ត្រូវមានឯកសារជាភ័ស្តុតាងបញ្ជាក់ទំនាក់ទំនងអំពីញាតិ ដូចមានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា៧.- ការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូន**

ត្រូវបានលើកលែងពន្ធប្រថាប់ត្រា ចំពោះការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

**មាត្រា៨.- ការបំពេញបែបបទនៅរដ្ឋបាលសារពើពន្ធ**

ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលត្រូវបានលើកលែងឬអនុគ្រោះពន្ធ ដូចមានកំណត់ក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ទោះបីជាមានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវបំពេញបែបបទនៅរដ្ឋបាលសារពើពន្ធ ទាំងអចលនទ្រព្យដែលបានចុះបញ្ជី និងមិនទាន់បានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី។

ក្នុងករណីអ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនោះ មិនបានបំពេញកាតព្វកិច្ចដូចមានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រានេះ ÷

- រដ្ឋបាលសុរិយោដីមិនត្រូវចេញឬផ្ទេរវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនោះទេ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) មិនត្រូវបញ្ជាក់លើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនោះទេ
- រដ្ឋបាលសុរិយោដី និងអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនរាល់ករណីស្នើសុំផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ ឱ្យមកបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទោះជាអចលនទ្រព្យបានចុះបញ្ជី ឬមិនបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដីក្តី។

ចំពោះការលើកលែងពន្ធប្រថាប់ត្រាដូចមានកំណត់ក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ មិនតម្រូវឱ្យមានការបំពេញបែបបទនៅរដ្ឋបាលសារពើពន្ធនោះទេ។

**មាត្រា៩.- ការណែនាំអនុវត្តអនុក្រឹត្យ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសនិងលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ឬណែនាំអំពីវិធាននិងនីតិវិធីនៃការអនុវត្តអនុក្រឹត្យនេះ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា១០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧៥....អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរបញ្ចូលមន្ត្រីរាជការចំនួន ០៣រូប ទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម:

១- លោក **អ៊ីម ណារ៉ុង** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៦

២- លោក **ពេជ្រ ភញ្ញនា** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៦

៣- លោក **ហេង គីមហៀង** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៦។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៧៦...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិមកជាឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្លាស់ប្តូរ និងតម្លើងឋានន្តរស័ក្តិលោកស្រី **នូ ថាវរី** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៩ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : តម្លើងឋានន្តរស័ក្តិលោក **អ៊ុំ លន** ពីឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ៣ មកជាឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ញឹក បានខេង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តកំពង់ធំ។

**មាត្រា ២ :** ក្នុងរយៈពេលមកបំពេញភារកិច្ចថ្មីនេះ លោក **ញឹក បានខេង** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ៣៦ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៦** ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **សឹម ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២-លោកជំទាវ **ពៅ វរលក្ស្មណ៍** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៣-លោក **ទឹង សុមិត្ត** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៤-ឯកឧត្តម **ចម បូរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥-លោក **ចាតស្វ សុភ័ក្ត្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៦-លោក **រដ្ឋ សារ៉ាវុធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៧-លោក **បុត្រ ភ័ក្ត្រសត្យា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៨-លោក **ម៉េង សេរីវ៉ាត់** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៩-លោក **ឌី ប៉ូលីននាវិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ១០-លោក **ម៉ៅ សុផល** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ១១-លោក **យា ប៊ុនណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ១២-លោក **នួវ ថារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៣-លោកស្រី **គង់ សិទ្ធិភា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៤-លោក **ញ៉ៀម ចន្ទូ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៥-លោក **សារិ ផល្លា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៦-លោក **កែ សារី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ១៧-លោក **ពឹង ឆេងលី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៨-លោក **ហេង សុធា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៩-លោក **ញឹម វណ្ណារុន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០-លោក **ង៉ែត វិបុល** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២១-លោក **ឆេង ឧត្តរា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២២-លោក **សេង ឆាង** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៣-លោក **អ៊ិន សំបូរ** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៤-លោក **ចាន់ សូផា** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ២៥-លោក **ប៊ី ពិទូរ្យ** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |

២៦-លោក **គឹម ច័ន្ទតារា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

២៧-លោក **ប៉ែន តារ៉ែត** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

២៨-លោក **ឡោ សត្យា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

២៩-លោក **ខៀវ ពេជ្រតារាវឌ្ឍី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣០-លោក **ទឹង ស៊ីនី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣១-លោក **ជួរ ជេតធីរ័ត្ន** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣២-លោក **គន់ សុខជា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣៣-លោក **អ៊ុំ ពៅពិសី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣៤-លោក **វ៉ាន់ ម៉ៅ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣៥-លោកស្រី **ផាន សោភា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៣៦-លោក **ហុក ឆី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៩ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតម្លើងឋានន្តរស័ក្ដិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន **២០១** រូប នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៦** ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថៃ ជុន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ២- លោក **អ៊ឹង រចនា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៣- លោក **គឹម សុវណ្ណា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៤- លោក **ហូ ពេជ្រមោលី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៥- លោកស្រី **កែវ សុរិត្ថា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៦- លោក **ស៊ិន ស៊ីយ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៧- លោក **ម៉ែន វណ្ណា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៨- លោក **ស៊ុន ដារិន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ៩- លោក **ស៊ុន សុធារ៉ាត** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១០- លោក **ខិល ដារ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១១- លោក **ហ្ស សុផារ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១២- លោកស្រី **ទូត គន្ធា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៣- លោក **សុត វណ្ណា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៤- លោកស្រី **ប៉ូ ស៊ីវត្ថា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៥- លោក **អេង ជា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៦- លោកស្រី **ស៊ុន ដារី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៧- លោក **ស៊ុន ដារិទ្ធ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៨- លោក **ទុយ ភាពិរៈ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ១៩- លោកស្រី **ថោង សុគន្ធារី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ២០- លោក **កៅ សំណាង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |

| | | |
|---|---|---|
| ២១- លោក **រ័ត្ន ចាន់វាសនា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ **២** | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ១ |
| ២២- ឯកឧត្តម **ពេជ្រឃុន បញ្ញា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៣- ឯកឧត្តម **នង សាកល** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៤- លោក **ភិន វិជ្ជាវឌ្ឍនា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៥- លោក **សៅ ខូវ៉ាឌីន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៦- លោក **អ៊ុក ចាន់ដាវ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៧- លោក **ប្រាក់ ង្វនហុង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៨- លោកស្រី **ទូច សុផារត្ន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ២៩- លោក **សោម វិសាល** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣០- លោក **ស៊ិន ប៊ុនធឿន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣១- លោក **គ្រុយ លីមហេង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣២- លោក **យៀប សំណាង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៣- លោក **ចឺយ វិចិត្ត** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៤- លោកស្រី **ពេជ្រ ពុទ្ធិសាធបូព៌ានាគី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៥- លោក **អៀម ពុទ្ធវិរោ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៦- លោក **សេង សុជាតិ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៧- លោកស្រី **កែវ សុផាន់ណាវ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៨- លោក **ខៀវ រិទ្ធីយ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៣៩- លោក **តាក សុវណ្ណនី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤០- លោក **ហេង ពៅ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤១- លោក **ផៃ គឹមឈាន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤២- លោក **សុខ ហ៊ីម** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤៣- លោកស្រី **សុខ សុបុត្ត** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤៤- លោក **នាង សំរិតកុមារ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |
| ៤៥- លោក **ប៊ុង សីហា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ **២** |

| | | |
|---|---|---|
| ៤៦- លោក ឃុន សុវណ្ណារិទ្ធ | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៤៧- លោក ខៃ លន | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៤៨- លោក សុខ ខឿន | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៤៩- លោក លី សុខអេង | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥០- លោក ឈាង ធីរ៉ា | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥១- លោក រិទ្ធ ចាន់អុល | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥២- លោក ឡុង សុខន | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥៣- លោកស្រី បាន បូរ៉ុម | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
| ៥៤- លោកស្រី ឯក ប៉ូលី | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកវរមន្ត្រីការបរទេស ថ្នាក់លេខ ២ |
